អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ព្រឹត្តិបត្រព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ អៀង សារី ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម និង អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

មេធាវីរបស់ពួកគេបានស្នើសុំពេលវេលាដើម្បីត្រៀមការពារក្តីរបស់ខ្លួន ហើយហេតុនេះ ពួកគេបានស្នើសុំឲ្យពន្យារពេលសវនាការស្តាប់ចម្លើយទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីបញ្ហាការឃុំខ្លួនមុនការជំនុំជម្រះ។

សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា សំណើនេះសមហេតុផល និងបានសម្រេចថា សវនាការស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយក្នុងអំឡុងពេលនេះ ជនត្រូវចោទទាំងពីររូបស្ថិតក្រោមការឃាត់ខ្លួនដោយនគរបាល នៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។
(http://www.eccc.gov.kh/english/indictments.list.aspx)

ថ្ងៃនេះ ជនត្រូវចោទទាំងពីររូបនឹងទទួលការពិនិត្យផ្នែកវេជ្ជសាស្ត្រនៅមន្ទីរពេទ្យកាល់ម៉ែត្រ។

ព័ត៌មានលម្អិតបន្ថែមទៀតនឹងជម្រាបនៅពេលដ៏ខ្លីខាងមុខ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh